**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គាំពារសង្គមកម្ពុជា**

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល(លើកទី៧)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ១២ ៧៦០នាក់ នៃរោងចក្រ សហគ្រាស ទាំង៣៤ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីងនឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ ដើម្បីចៀសវាងការលំបាកក្នុងការបង្វិលថវិកាសងរាជរដ្ឋាភិបាលវិញ ក្នុងករណីរោងចក្រ សហគ្រាសសុំចូលធ្វើការមុនកាលកំណត់នៃរយៈពេលព្យួរកិច្ចសន្យាការងារ នោះប្រាក់ឧបត្ថម្ភនឹងត្រូវចែកចេញជា ២ដង សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងារចាប់ពី ២១ថ្ងៃ ដល់ ១ខែ, និងត្រូវបែងចែកជា ៤ដង សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ដោយក្នុង ១ដង ស្មើនឹងថវិកាចំនួន ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក)។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៣៤ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

*ថ្ងៃ អង្គារ ៣កើត ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០២០*

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨៤ ៣៧៥ និងទូរសារ:(០២៣) ៨៨ ២៧ ៦៩*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៣ខែមិថុនា ឆ្នាំ២០២០

### បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ៣៤ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 15 |
| 1 | ក្រុមហ៊ុនប៊ីយូធី ស៊ីល ស្ព្រីន លីមីធីត | ភ្នំពេញ |
| 2 | ក្រុមហ៊ុនជា ស៊ុណាត ហ្គាមេន ខូ អិលធីឌី | ភ្នំពេញ |
| 3 | ក្រុមហ៊ុនជីឌីអិម អ៊ិនធើប្រាយ | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ហុង វ៉ែន (ខេមបូឌា) ហ្គាមេន | ភ្នំពេញ |
| 5 | ក្រុមហ៊ុនគុយប៉ូ(ខេមបូឌា) | ភ្នំពេញ |
| 6 | ក្រុមហ៊ុនកាឡាខេម អ៊ិនវែសមេន ខូអិលធីឌី | កំពង់ស្ពឺ |
| 7 | ក្រុមហ៊ុនចិចសាន់(ខេមបូឌា)នីតធីង វ៉ស៊ីង ដាយអ៊ីង អេន ព្រីនធីង ឯ.ក | កំពង់ស្ពឺ |
| 8 | ក្រុមហ៊ុន ហុន ធីហ្សី ហ្វ៊ុង (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 9 | ក្រុមហ៊ុន ហេង ស៊ីម ហ្វ៊ួត វែរ ឯ.ក | កំពង់ស្ពឺ |
| 10 | ក្រុមហ៊ុនជីវ ហ្សី ហ្គាម៉ិន ឯ.ក | កណ្ដាល |
| 11 | ក្រុមហ៊ុន ខេមបូ យូនីសូល អិលធីឌី | កណ្ដាល |
| 12 | ក្រុមហ៊ុនវ៉ាយ អិម ជី ហ្គាមេន អេកសេសើរី | កណ្ដាល |
| 13 | ក្រុមហ៊ុន អេសអ៊ីអ៊ីអេស គ្លូបល(ខេមបូឌា)ខូ អិលធីឌី | កណ្ដាល |
| 14 | ក្រុមហ៊ុនឡាយហ្វេងអៅដរ(ខេមបូឌា)ឯ.ក | តាកែវ |
| 15 | ក្រុមហ៊ុនខាលីងតុន (ខេមបូឌា).ខូអិលធីឌី | កំពង់ចាម |
| ខ. វិស័យទេសចរណ៍ | | 19 |
| 16 | ក្រុមហ៊ុនវីណា ហុងកុង ខំផែនី អែលធីឌី | ភ្នំពេញ |
| 17 | សណ្ឋាគារ អូឡាំព្យា ស៊ីធី ហូថេល | ភ្នំពេញ |
| 18 | ក្រុមហ៊ុនអិល&អិម បាសាក់ រីវើរ ខូ អិលធីឌី | ភ្នំពេញ |
| 19 | ក្រុមហ៊ុនបាអាតហ្គូត ឯ.ក | ភ្នំពេញ |
| 20 | ក្រុមហ៊ុន សិប្បករអង្គរ | ភ្នំពេញ |

| ល.រ | ឈ្មោះពាណិជ្ជកម្ម សហគ្រាស | រាជធានី ខេត្ត |
| --- | --- | --- |
| 21 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |
| 22 | សណ្ឋាគារ លីនាយាអង្គរ រីសត និងស្ប៉ា | សៀមរាប |
| 23 | ក្រុមហ៊ុនអង្គរ សេនជូរី គ្រុប ភីធីអ៊ី អែលធីឌី | សៀមរាប |
| 24 | ក្រុមហ៊ុនស៊ីវ៉ាយ-អេសអ ហូថេល ហ្វ្រេន ឡាយអិន ឯ.ក | សៀមរាប |
| 25 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 26 | ក្រុមហ៊ុនសិប្បករអង្គរ | សៀមរាប |
| 27 | ក្រុមហ៊ុនអង្គរ ហូលីដេ | សៀមរាប |
| 28 | ក្រុមហ៊ុនឡូទុស ប្លង្គ រីសត | សៀមរាប |
| 29 | សណ្ឋាគារវិគ្ទរីយ៉ាអង្គរ រីសត និង ស្ប៉ា | សៀមរាប |
| 30 | សណ្ឋាគារដឺឡាពេ (ផាកហៃយ៉ាត់សៀមរាប) | សៀមរាប |
| 31 | ក្រុមហ៊ុន ឥណ្ឌូឆាយណា ស៊ីវីសស៍ (ខេមបូឌា) លីមីតធីត | សៀមរាប |
| 32 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 33 | សណ្ឋាគារ អង្គរមីរ៉ាខល រីហ្សត និង ស្ប៉ា | សៀមរាប |
| 34 | ក្រុមហ៊ុន បុរី អង្គរ | សៀមរាប |